ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
គណៈកម្មការជ្រើសរើសពលទាហាន
បំពេញក្របខណ្ឌឲ្យយោធភូមិភាគទី១
កងទ័ពជើងគោក
លេខ: ១៧៥៩/សាងសា/២០១៧

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី៖ ការទប់ស្កាត់ក្នុងករណីមានបុគ្គលមួយចំនួនឆ្លៀតឱកាសកេងចំណេញ នៅក្នុងដំណើរការជ្រើសរើសពលទាហាន ដើម្បីបំពេញក្របខណ្ឌ ឲ្យយោធភូមិភាគទី១ កងទ័ពជើងគោក

គណៈកម្មការជ្រើសរើសពលទាហានបំពេញក្របខណ្ឌឲ្យយោធភូមិភាគទី១ កងទ័ពជើងគោក មានកិត្តិយស សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសយុវជន ដែលមានបំណងចូលបម្រើការងារជាយោធិននៃកងយោធពលខេមរភូមិន្ទឲ្យបានជ្រាបថា ៖ ដើម្បីផ្តល់ឱកាសប្រកបដោយតម្លាភាព និងយុត្តិធម៌ដល់យុវជនទូទៅ ក្នុងការដាក់ពាក្យចូលបម្រើក្នុងកងយោធពលខេមរភូមិន្ទ ផ្អែកតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងការកំណត់របស់ក្រសួងការពារជាតិ ជាពិសេសដើម្បីចូលរួមទប់ស្កាត់ក្នុងករណីមានបុគ្គលមួយចំនួនឆ្លៀតឱកាសកេងចំណេញតាមរយៈការធ្វើសកម្មភាពប្រមូលលុយកាក់ផ្សេងៗ ប្រាសចាកគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល និងក្រសួងការពារជាតិ គណៈកម្មការជ្រើសរើសពលទាហាន សូមអំពាវនាវដល់សាធារណជននិងបេក្ខជនទាំងអស់ ចូលរួមផ្តល់កិច្ចសហការជាមួយគណៈកម្មការ តាមរយៈការផ្តល់ព័ត៌មានជាបន្ទាន់ ក្នុងករណីមានបុគ្គលណាទារលុយ ឬ តម្រូវឲ្យបេក្ខជនបង់ប្រាក់ជាថ្នូរនឹងការដាក់ពាក្យ ដើម្បីទទួលបានក្របខណ្ឌចូលបម្រើការ។

គណៈកម្មការជ្រើសរើសពលទាហាន សូមធ្វើការបញ្ជាក់ជាថ្មីម្តងទៀតថា ៖ រាល់ការស្ម័គ្រចិត្តដាក់ពាក្យសុំបម្រើការក្នុងកងយោធពលខេមរភូមិន្ទនេះ គឺមិនតម្រូវឲ្យបេក្ខជនបង់ប្រាក់ឡើយ ដោយគិតពីការចាប់ផ្តើមដាក់ពាក្យ រហូតបានសម្រេចចូលក្របខណ្ឌ រួមទាំងការពិនិត្យសុខភាព កាយសម្បទា និងលិខិតស្នាមពាក់ព័ន្ធផ្សេងៗ។ រាល់បុគ្គលដែលប្រព្រឹត្តខុសទៅនឹងគោលការណ៍ខាងលើ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

ករណីមានបុគ្គលឆ្លៀតឱកាសដូចជម្រាបជូនខាងលើ សូមសាធារណជន និងបេក្ខជនសហការផ្តល់ព័ត៌មានមកក្រុមការងារដោយផ្ទាល់ តាមទូរស័ព្ទលេខ **085333944 / 085222744 / 0972666241 /0972666240 / 086847300 / 086685570** ។

គណៈកម្មការជ្រើសរើសពលទាហានបំពេញក្របខណ្ឌឲ្យយោធភូមិភាគទី១ កងទ័ពជើងគោក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាធារណជន និងបេក្ខជនទាំងអស់ ដែលផ្តល់កិច្ចសហការគាំទ្រនានាដល់កិច្ចដំណើរការជ្រើសរើសពលទាហាននេះ ទទួលបានជោគជ័យ និងប្រសិទ្ធភាពខ្ពស់។

**គណៈកម្មការជ្រើសរើសពលទាហាន**